**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

នារសៀលថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **ឯកឧត្តម អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញចូលរួមកិច្ចប្រជុំពិសេសថ្នាក់រដ្ឋមន្ត្រីការងារអាស៊ាន ស្តីពី **"ការឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើមុខរបរ និងការងារ"** តាមរយៈប្រព័ន្ធវីដេអូ (Video Conference) ដែលមានរដ្ឋមន្ត្រីក្រសួងធនធានមនុស្សប្រទេសម៉ាឡេស៊ី ក្នុងអាណត្តិជាប្រធាន បានដឹកនាំកិច្ចប្រជុំនេះ។

នៅក្នុងកិច្ចប្រជុំពិសេសនេះ **ឯកឧត្តមរដ្ឋមន្ត្រី** បានចែករំលែកព័ត៌មានអំពីគោលនយោបាយ និងវិធានការនានាដែលរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញ ដើម្បីបង្ការនិងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងជួយឧបត្ថម្ភគាំទ្រដល់កម្មករនិយោជិត និយោជក និងជនងាយរងគ្រោះដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ នេះ។

ជាលទ្ធផល រដ្ឋមន្ត្រីការងារអាស៊ានបានអនុម័តសេចក្តីថ្លែងការណ៍រួមស្តីពី **"ការឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើមុខរបរ និងការងារ"** ដែលមាន ៩ចំណុច ក្នុងនោះផ្តោតសំខាន់ទៅលើការផ្តល់កិច្ចគាំទ្រដល់ជីវភាព និងសុខភាពរបស់កម្មករនិយោជិត ពលករទេសន្តរប្រវេសក៍ និងអ្នកធ្វើការក្នុងវិស័យដែលរងហានិភ័យខ្ពស់, ការធានាថាកម្មករនិយោជិតដែលត្រូវបានបញ្ឈប់ ឬព្យួរកិច្ចសន្យាការងារ ទទួលបាននូវអត្ថប្រយោជន៍សមស្របតាមច្បាប់ លិខិតបទដ្ឋាន និងលទ្ធភាពនៃប្រទេសជាសមាជិក, ការផ្តល់សេវាថែទាំសុខភាពដល់កម្មករនិយោជិតដែលបានឆ្លងជំងឺកូវីដ-១៩, ការពង្រឹងបន្ថែមប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយទីផ្សារការងារ បទដ្ឋានសុវត្ថិភាពនិងសុខភាពការងារ និងប្រព័ន្ធគាំពារសង្គម, និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលជាមធ្យោបាយក្នុងការទំនាក់ទំនង និងពិគ្រោះយោបល់ក្នុងអំឡុងពេលមានការរឹតត្បិតជាបណ្តោះអាសន្ន។

កិច្ចប្រជុំពិសេសនេះ គឺបង្ហាញពីភាពរឹងមាំនៃស្មារតីសាមគ្គីភាពរបស់ប្រទេសជាសមាជិកអាស៊ាន ដូចមានចែងក្នុងបាវចនាអាស៊ាន "**សហគមន៍តែមួយ វាសនាតែមួយ**" ក្នុងការឆ្លើយតបរួមគ្នារបស់អាស៊ាន ចំពោះផលប៉ះពាល់នៃជំងឺកូវីដ-១៩។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារៈ(០២៣) ៨៨ ២៧ ៦៩